ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១៦ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងាររៀបចំសុខដុមនីយកម្ម នៃមុខងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចនៅតាមក្រសួង-ស្ថាប័ន

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១១ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីច្បាប់បន្ថែមទៅលើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញសារាចរណែនាំលេខ ១២ សរណន ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការបន្តពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ស្តីអំពីការពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងាររៀបចំសុខដុមនីយកម្ម នៃមុខងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច នៅតាមក្រសួង-ស្ថាប័ន ដែលហៅកាត់ថា "**ក.ស.អ.**" ដើម្បីលើកកម្ពស់សុខដុមនីយកម្មនិងប្រសិទ្ធភាព នៃការអនុវត្តមុខងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចនៅតាមក្រសួង-ស្ថាប័ន ដែលស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

**ប្រការ២.-**

**ក.ស.អ.** មានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តម **ទី តាយី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម **ហ៊ែល ចំរើន** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. ឯកឧត្តម **ឆាយ រតនៈ** | អគ្គាធិការ នៃអគ្គាធិការដ្ឋាន | សមាជិក |
| ៤. ឯកឧត្តម **ជា ទុធណា** | អគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ៥. លោក **យ៉េត ទីណែល** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ៦. លោក **គង់ ទឡ្ហនៈ** | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន | សមាជិក |
| ៧. លោក **គីម្ហា សុផុន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ៨. លោក **រស់ សុខណារុណា** | អនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម | សមាជិក |
| ៩. លោក **ស៊ុំ ផល** | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១០.លោក **ហោ ស៊ីនឡេង** | អនុប្រធានការិយាល័យ នៃអគ្គាធិការដ្ឋាន | សមាជិក |
| ១១.លោក **លី ទ៉ុង** | មន្ត្រីជំនាញជាន់ខ្ពស់នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក/លេខាធិការ |
| ១២. លោក **ទី ទិន្ន** | មន្ត្រីក្រុមប្រឹក្សាជាតិគណនេយ្យ | សមាជិក។ |

**ប្រការ៣.-**

គ.ស.អ. មានភារកិច្ចដូចតទៅ÷

- ពិនិត្យនិងសិក្សាអំពីលិខិតបទដ្ឋានគតិយុត្តជាធរមាន និងការអនុវត្តជាក់ស្តែងពាក់ព័ន្ធមុខងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច នៅតាមក្រសួង-ស្ថាប័ន
- ផ្តល់អនុសាសន៍ និង/ឬ ជំនួយបច្ចេកទេសពាក់ព័ន្ធការរៀបចំសុខដុមនីយកម្ម នៃមុខងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច ជូនដល់ក្រសួង-ស្ថាប័ន
- ផ្សព្វផ្សាយ ណែនាំអនុវត្ត និងលើកកម្ពស់ប្រសិទ្ធភាពនៃការធានាសុខដុមនីយកម្ម នៃមុខងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច ជូនដល់ក្រសួង-ស្ថាប័ន
- សិក្សាស្រាវជ្រាវនិង/ឬធ្វើទស្សនកិច្ចសិក្សាអំពីបទពិសោធន៍និងឧត្តមានុវត្តន៍អន្តរជាតិ ពាក់ព័ន្ធសុខដុមនីយកម្មនៃមុខងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច
- បំពេញភារកិច្ចផ្សេងទៀត ពាក់ព័ន្ធនឹងការងាររៀបចំសុខដុមនីយកម្មមុខងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៤.-**

សមាជិក នៃ **គ.ស.អ.** ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ, អនុប្រធានប្រចាំការ ឬ អនុប្រធាន ដឹកនាំការងារជំនួស តាមការផ្ទេរសិទ្ធិរបស់ប្រធាន។

**គ.ស.អ.** អាចអញ្ជើញមន្ត្រីជំនាញពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមិនមែនជាសមាជិក ឱ្យចូលរួមប្រជុំ តាមតម្រូវការចាំបាច់នៃការងារ។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់ក្រសួងស្ថាប័ន ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

...ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៧

អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

៣